# សារលិខិត

## សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន

## ប្រធានកាកបាទក្រហមកម្ពុជា និងជាឥស្សរជនឆ្នើមថ្នាក់ជាតិ

## នៃផែនការសកម្មភាពរួមអគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីសុខភាពស្ត្រី និងកុមារ

### ក្នុងឱកាសទិវាជាតិ សុខភាពមាតា ទារក និងកុមារ ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២៥

### ក្រោមប្រធានបទ "ពង្រឹងភាពជាដៃគូរវាងសេវាសុខាភិបាលសាធារណៈ និងសេវាឯកជន ដើម្បីលើកកម្ពស់គុណភាពនៃការថែទាំសុខភាពមាតា ទារក កុមារ និងយុវវ័យ"

*សូមគោរព៖*

- *សម្តេច ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា*
- *បង-ប្អូន ជនរួមជាតិ ជាទីស្រឡាញ់រាប់អាន និងជាទីនឹករលឹក!*

ក្នុងឱកាសដ៏ប្រសើរថ្លៃថ្លា នៃទិវាជាតិសុខភាពមាតា ទារក និងកុមារ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៥នេះ ក្នុងនាមកាកបាទក្រហមកម្ពុជា និងជាឥស្សរជនឆ្នើមថ្នាក់ជាតិនៃផែនការសកម្មភាពរួមអគ្គលេខាធិការអង្គការសហប្រជាជាតិដើម្បីសុខភាពស្ត្រី និងកុមារ ខ្ញុំមានក្តីសោមនស្សរីករាយ សូមចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា និងបង-ប្អូនជនរួមជាតិទាំងអស់ ដើម្បីអបអរសាទរទិវាជាតិសុខភាពមាតា ទារក និងកុមារ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃសុក្រ ៩រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៥ ក្រោមប្រធានបទ "ពង្រឹងភាពជាដៃគូរវាងសេវាសុខាភិបាលសាធារណៈ និងសេវាឯកជន ដើម្បីលើកកម្ពស់គុណភាពនៃការថែទាំសុខភាពមាតា ទារក កុមារ និងយុវវ័យ"។ ប្រាកដណាស់ប្រធានបទនេះ គឺត្រូវពេលវេលា និងឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ក្រសួងសុខាភិបាលក្នុងការអនុវត្តវិធានការគន្លឹះនានា ស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។

ជាការពិតណាស់ ក្នុងឆ្នាំ២០២៤កន្លងទៅនេះ ព្រះរាជាណាចក្រកម្ពុជាសម្រេចបានសមិទ្ធផលធំៗជាច្រើន ដោយសារប្រទេសជាតិមានសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព មានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធ្វើឱ្យប្រជាពលរដ្ឋអាចប្រកបរបរជំរុញជីវភាពគ្រួសារ និងសង្គមបានប្រសើរជាងមុន។

ជាមួយនឹងភាពជាអ្នកដឹកនាំដ៏ឈ្លាសវៃ និងការអនុវត្តដ៏មានប្រសិទ្ធភាព នៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទីមួយ រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយការពារសង្គម ជាពិសេសដើម្បីគាំទ្រដល់ក្រុមដែលងាយរងគ្រោះ។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជា បានពង្រីកវិសាលភាពនៃការគ្របដណ្តប់សេវាសុខាភិបាលជាសកលនៅកម្ពុជា។

ការបន្តធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ ការពង្រឹងនិងបន្តអភិវឌ្ឍប្រព័ន្ធសុខាភិបាល ព្រមទាំងការបន្តវិនិយោគលើធនធានមនុស្សក្នុងវិស័យសុខាភិបាល និងបច្ចេកវិទ្យា វេជ្ជសាស្ត្រទំនើប ជាគន្លឹះចាំបាច់ក្នុងការធ្វើឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានសេវាថែទាំសុខភាព ការព្យាបាលប្រកបដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់។ ជាមួយនឹងការពង្រឹង និងកែលម្អសេវាសុខាភិបាលសាធារណៈនៅមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកស្រុក

ឡូត៍ ១៦A ផ្លូវលេខ៦៥២ កែង២៧១ អូរបែកក្អម សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Lot: 16A, Street 652@271, O Bek Kaam, Sangkat Toek Laak 3, Khan Tuol Kork, Phnom Penh, Kingdom of Cambodia
Tel: (855-23)881 511, Fax: (855-23)881 522, P.O. Box: 69, Web: www.redcross.org.kh, Facebook: www.facebook.com/crcnhq, Email: info@redcross.org.kh, crc_adm@online.com.kh

មន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យជាតិ ការចូលរួមជាដៃគូពីសេវាសុខាភិបាលឯកជនក្នុងប្រព័ន្ធសុខាភិបាល យើងបានផ្ដល់នូវការទទួលបានសេវាវេជ្ជសាស្ត្រដែលមានគុណភាពកាន់តែប្រសើរ ជាពិសេសក្នុងការថែទាំសុខភាពមាតា ទារក កុមារ និងយុវវ័យនៅកម្ពុជា។

ទោះបីជាយើងទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ក៏ដោយ ក៏យើងនៅតែត្រូវប្រឹងប្រែងបន្ថែមទៀត ដើម្បីធ្វើឱ្យសេវាថែទាំសុខភាពរបស់យើងកាន់តែល្អប្រសើរឡើង និងផ្សព្វផ្សាយទៅកាន់មនុស្សកាន់តែច្រើនថែមទៀត ក្រោមពាក្យស្លោក "ជីវិតមានសុខភាពល្អ កម្ពុជានឹងមានការរីកចម្រើន"។ សង្គមមានសុខភាពល្អ ជាគ្រឹះនៃការអភិវឌ្ឍប្រកបដោយនិរន្តភាព។ ដើម្បីឱ្យកម្ពុជាសម្រេចទស្សនវិស័យក្លាយជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ ចាំបាច់ត្រូវវិនិយោគធនធានក្នុងការលើកស្ទួយសង្គមជាតិឱ្យមានសុខភាពល្អ។ អាស្រ័យហេតុនេះ ក្នុងឱកាសដ៏មហោឡារឹកនៃទិវាជាតិសុខភាពមាតា ទារក និងកុមារ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៥ នេះ ខ្ញុំសូមអំពាវនាវចំពោះបង-ប្អូន ជនរួមជាតិ និងអ្នកពាក់ព័ន្ធទាំងអស់ សូមចូលរួមសហការជាមួយក្រសួងសុខាភិបាល អនុវត្តសកម្មភាពដូចខាងក្រោម៖

១. យើងត្រូវលើកកម្ពស់ការយល់ដឹងបន្ថែមទៀត៖
- សូមឱ្យស្ត្រីមានផ្ទៃពោះ ទៅពិនិត្យសុខភាពយ៉ាងតិច៤ដង តាមពេលវេលាកំណត់ដើម្បីទទួលបានការពិនិត្យថែទាំ ទទួលបានវ៉ាក់សាំងបង្ការជំងឺ ធ្វើតេស្តដោយស្ម័គ្រចិត្តរកមេរោគដើម្បីលុបបំបាត់ការចម្លងមេរោគអេដស៍/ស្វាយពីម្ដាយទៅកូន និងត្រូវទៅសម្រាលកូននៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលមានគ្រូពេទ្យទទួលបានការបណ្ដុះបណ្ដាលជំនាញត្រឹមត្រូវ។
- ក្រោយពេលសម្រាល សូមស្ត្រីជាមាតាទៅពិនិត្យសុខភាពដោយយកកូនទៅពិនិត្យផង តាមកាលកំណត់ ដើម្បីទទួលវ៉ាក់សាំងបង្ការជំងឺទាំង១១មុខ ពិនិត្យតាមដានសុខភាពនិងការលូតលាស់របស់កូន។ សូមបំបៅកូនដោយទឹកដោះម្ដាយតែមួយមុខគត់ ចាប់ពីទារកកើតភ្លាមរហូតដល់ទារកមានអាយុ៦ខែ និងផ្ដល់អាហារបន្ថែមគ្រប់មុខគ្រប់ជីវជាតិ រួមជាមួយការបន្តបំបៅទឹកដោះម្ដាយរហូតដល់កុមារមានអាយុយ៉ាងតិច២ឆ្នាំ។
- សូមប្រញាប់យកទារក ឬកុមារទៅមន្ទីរពេទ្យភ្លាម នៅពេលឃើញសញ្ញាគ្រោះថ្នាក់ណាមួយនៃជំងឺរលាកផ្លូវដង្ហើម ជំងឺរាក ឬជំងឺផ្សេងទៀត និងយកទារក ឬកុមារតូចដែលមានរាងកាយស្គម ឬមិនឡើងទម្ងន់ ទៅពិគ្រោះយោបល់ជាមួយគ្រូពេទ្យជំនាញ និងទទួលការពិនិត្យ និងព្យាបាលនៅមន្ទីរពេទ្យ។
- សូមយុវជន-យុវតី និងស្ត្រីក្នុងវ័យបន្តពូជ ទៅពិគ្រោះយោបល់ ទទួលការណែនាំ ការពិនិត្យ ឬព្យាបាលជំងឺនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ ឬគ្លីនិកដែលមានគ្រូពេទ្យជំនាញត្រឹមត្រូវ។ សូមចូលរួមក្នុងការទប់ស្កាត់ និងលុបបំបាត់ការចម្លងមេរោគអេដស៍ ស្វាយ រលាកថ្លើមប្រភេទបេពីឪពុកម្ដាយទៅកូន និងចូលរួមក្នុងការទប់ស្កាត់ជំងឺមហារីកមាត់ស្បូន ដោយនាំកុមារីអាយុ៩ឆ្នាំទៅទទួលវ៉ាក់សាំងបង្ការជំងឺមហារីកមាត់ស្បូនឱ្យបានគ្រប់ៗគ្នា។

២. សូមនាយកគ្រឹះស្ថានឯកជនដែលផ្ដល់សេវាសុខាភិបាល ដូចជាបន្ទប់ថែទាំ មន្ទីរសម្រាកព្យាបាល មន្ទីរសម្ភព មន្ទីរពហុព្យាបាល ឱសថស្ថានឯកជន ត្រូវចូលរួមសហការជាមួយក្រសួងសុខាភិបាល ឬអង្គភាពពាក់ព័ន្ធក្នុងការគាំទ្រ ផ្ដល់បច្ចេកទេស ផ្ដល់សេវាប្រកបដោយគុណភាពជូនស្ត្រី មាតា ទារក និងកុមារ ក្នុងភាពជាដៃគូ និងក្នុងស្មារតីទទួលខុសត្រូវ ដើម្បីភាពរីកចម្រើននៃវិស័យសុខាភិបាលនៅកម្ពុជា។ ភាពជាដៃគូពហុភាគីពាក់ព័ន្ធមានសារៈសំខាន់ក្នុងការផ្ដល់លទ្ធផលបន្ថែមទៀត។

៣. សូមអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ ត្រូវយកចិត្តទុកដាក់ជំរុញ និងបញ្ជូនស្ត្រីក្នុងវ័យបន្តពូជ ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនអាយុក្រោម២ឆ្នាំ មកទទួលសេវាថែទាំសុខភាពនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកឱ្យបានគ្រប់ៗគ្នា។ ជាមួយគ្នានេះ ត្រូវជួយជំរុញស្ត្រីឱ្យមកទទួលសេវាបន្តតាមការណាត់ជួបរបស់ឆ្មប ឬគ្រូពេទ្យ និងសូមជួយតាមរកស្ត្រីដែលអាក់ខានមិនបានមកទទួលសេវា ឬបោះបង់សេវា ឱ្យមកទទួលសេវា និងថ្នាំព្យាបាលតាមការកំណត់។ ក្នុងន័យនេះ ត្រូវចូលរួមគាំទ្រការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

៤. សូមថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកសុខាភិបាល គ្រូពេទ្យ ឆ្មប អ្នកផ្តល់សេវាសុខាភិបាលទាំងអស់ ត្រូវមានភារកិច្ចអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងសម្រេចតាមគោលដៅកំណត់។ អ្នកផ្តល់សេវាថែទាំសុខភាពដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ការផ្តល់សេវាការថែទាំសុខភាពប្រកបដោយគុណភាព និងការផ្សព្វផ្សាយដល់អ្នកដែលត្រូវការជំនួយ។

៥. សូមមន្ត្រី បុគ្គលិក អ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា ចូលរួមសហការឱ្យបានជិតស្និទ្ធជាមួយមន្ត្រីបុគ្គលិកសុខាភិបាល ក្នុងការជួយអប់រំផ្សព្វផ្សាយសារអប់រំសុខភាព និងជួយតាមដានជំរុញ បញ្ជូនស្ត្រី ឬយុវតីឱ្យមកទទួលសេវានៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យឱ្យបានទាន់ពេលវេលា ឬតាមការណាត់ជួបកុំបីខាន។

៦. សូមស្ថាប័នជាតិ អន្តរជាតិ អង្គការជាដៃគូពាក់ព័ន្ធទាំងអស់ គាំទ្រដល់ភាពជាដៃគូរវាងសេវាសាធារណៈ និងឯកជន បន្តវិនិយោគទាំងផ្នែកបច្ចេកទេស និងថវិកា លើការងារថែទាំសុខភាពមាតា ទារក កុមារ និងយុវវ័យ ដើម្បីសម្រេចបានការគ្របដណ្តប់ការពិនិត្យថែទាំសុខភាពជាសកលនៅកម្ពុជា។

ខ្ញុំមានក្តីសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា រាជរដ្ឋាភិបាលកម្ពុជានឹងសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀតក្នុងឆ្នាំ២០២៥នេះ ក្រោមការដឹកនាំ ដែលមានថាមពល ប្រាជ្ញា និងចក្ខុវិស័យ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ វាមានសារៈសំខាន់សម្រាប់រាជរដ្ឋាភិបាលក្នុងការវិនិយោគធនធានបន្ថែមទៀត ក្នុងការលើកកម្ពស់សេវាសុខភាពសាធារណៈ។ យើងមិនអាចអភិវឌ្ឍប្រទេសរបស់យើង ដោយគ្មានមនុស្សដែលមានសុខភាពល្អនោះទេ។

ខ្ញុំសូមអរគុណជាអនេកចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសុខាភិបាល ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អង្គការជាតិ អន្តរជាតិ កាកបាទក្រហមកម្ពុជា សង្គមស៊ីវិល វិស័យឯកជន អាជ្ញាធរដែនដី កងកម្លាំងមានសមត្ថកិច្ច និងសប្បុរសជនទាំងអស់ដែលបាន និងកំពុងគាំទ្រដល់ការងារសុខភាពមាតា ទារក និងកុមារ។ រួមគ្នា យើងអាចសម្រេចបានកាន់តែច្រើន។ យើងទាំងអស់គ្នាអាចរួមគ្នាកសាងសង្គមមួយប្រកបដោយសុខភាពល្អ។ រួមគ្នា យើងអាចសម្រេចបាននូវចក្ខុវិស័យ ឆ្នាំ២០៥០ របស់យើង។

ខ្ញុំសូមឧទ្ទិសខ្លឹមសារ និងអត្ថន័យនៃទិវាជាតិសុខភាពមាតា ទារក និងកុមារ ឱ្យស្ថិតនៅជាប់ជាមួយយើងជានិច្ច ដើម្បីជំរុញការអនុវត្តសកម្មភាពទាំងអស់ឱ្យសម្រេចបានគោលដៅតាមការកំណត់ទុក៕

ថ្ងៃអង្គារ ៦រោច ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០២៥

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន**